ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ៧៥០ ព.ណ.ករ.ចប

ភ្នំពេញ, ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៥

# សេចក្តីជូនដំណឹង

អនុលោមតាមច្បាប់ ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រគួតប្រជែងមិនស្មោះត្រង់ និងប្រកាសលេខ ០៩៥ MOC/ SM 2011 ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១១ ស្តីពី ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ក្នុងព្រះរាជាណាចក្រកម្ពុជា ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកដែលបានទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម និងរូបវន្តបុគ្គលដែលបានបណ្តុះបណ្តាល និងបានប្រឡងជាប់ជាស្ថាពរ ហើយមានបំណងក្លាយជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក សូមអញ្ជើញមកដាក់ពាក្យស្នើសុំចុះបញ្ជីទទួលស្គាល់ តាមច្បាប់ និងប្រកាសដែលបានកំណត់ជាធរមាន ចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥ ។

ការដាក់ពាក្យស្នើសុំចុះបញ្ជីទទួលស្គាល់ជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកសម្រាប់ឆ្នាំ ២០១៥ នេះ ពុំមានការគិតកម្រៃចុះបញ្ជីឡើយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមភ្នាក់ងារតំណាងទាំងអស់ជ្រាបជាព័ត៌មាន។

ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ,ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sankat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
ទូរស័ព្ទ / ទូរសារ:(៨៥៥)-២៣ ៨៦៦ ៤៦៩
*Phone/Facsimile: (855)-23 866 469*